ព្រឹទ្ធសភា

អគ្គលេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍

# ស្ដីពី

# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែធ្នូ ឆ្នាំ២០២១ និងទិសដៅការងារខែមករា ឆ្នាំ២០២២

នៅក្នុងខែធ្នូនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងប្រក្រតីភាពថ្មី លើវិស័យនៃការងារសំខាន់ៗជាច្រើន ដើម្បីផ្ដល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០២លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញចំនួន០១លើក ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្ដីព្រាងច្បាប់ចំនួន០៣ច្បាប់៖

១-សេចក្ដីព្រាងច្បាប់ស្ដីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២

២-សេចក្ដីព្រាងច្បាប់ស្ដីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២០

៣-សេចក្ដីព្រាងច្បាប់ស្ដីពី ការអនុម័តយល់ព្រមលើពិធីសារអាស៊ានស្ដីពី ការពង្រឹងយន្តការដោះស្រាយវិវាទ

- បានទទួលសេចក្ដីព្រាងច្បាប់ចំនួន០៣ច្បាប់ ពីរដ្ឋសភា ព្រមទាំងចាត់ចែង តាមនីតិវិធី

- បានទទួលព្រះរាជក្រឹត្យ សេចក្ដីសម្រេច សេចក្ដីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន២៥៧ច្បាប់

-បានផលិតឯកសារជំនួយស្មារតីលើសេចក្ដីព្រាងច្បាប់ចំនួន០៣ច្បាប់

- បានធ្វើកំណត់បង្ហាញអនុក្រឹត្យ របាយការណ៍សវនកម្ម សេចក្ដីជូនដំណឹង ប្រកាស និងលិខិតផ្សេងៗចំនួន៣៥ច្បាប់



វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
oumsarith_sgsenate@yahoo.com

- បានធ្វើកំណត់បង្ហាញលើសេចក្តីព្រាងច្បាប់ មកពីក្រសួងធម្មការ និងសាសនាស្តីពីសាសនាក្នុងព្រះរាជាណាចក្រកម្ពុជា

- បានធ្វើប្រតិទិនសម័យប្រជុំព្រឹទ្ធសភា នីតិកាលទី៤ (២០២១-២០២៤)

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចចំនួន១៨លើក។

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនគណៈកម្មការទី៧ព្រឹទ្ធសភា ជួបប្រជុំពិភាក្សាការងារជាមួយឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ ជួនណារ៉ុន** រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ដើម្បីឈ្វេងយល់អំពីការវិវឌ្ឍ បញ្ហាប្រឈម និងចក្ខុវិស័យទៅមុខរបស់ក្រសួង ពិសេសគោលនយោបាយ សកម្មភាពអាទិភាពក្នុងបរិបទវិបត្តិជំងឺកូវីដ-១៩ ការស្តារសេដ្ឋកិច្ចឡើងវិញក្នុង និងក្រោយវិបត្តិជំងឺកូវីដ-១៩ និងវិធានការចាំបាច់នានា របស់ក្រសួងអប់រំ យុវជន និងកីឡា

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរគណៈកម្មការទី៨ព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្ម ដើម្បីសិក្សាឈ្វេងយល់ពីការប្រមូលព័ត៌មាន ការផ្សព្វផ្សាយច្បាប់ និងការអនុវត្តច្បាប់ពាក់ព័ន្ធនឹងវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តតាកែវ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរគណៈកម្មការទី១ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្ម ដើម្បីតាមដាន និងជំរុញការដោះស្រាយពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋ និងឈ្វេងយល់អំពីសិទ្ធិទទួលបានសុខភាព ពិសេសស្ត្រី និងកុមារក្នុងកំឡុងពេលមានវិបត្តិកូវីដ-១៩ នៅខេត្តបន្ទាយមានជ័យ។

**៣- មុខងារតំណាង**

- បានផ្តល់សេវា និងអមដំណើរ**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** អញ្ជើញចូលរួមប្រកួតកីឡាវាយកូនគោល (ពានរង្វាន់សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីលើកទី៥) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅទីលានវាយកូនគោលវឌ្ឍនហ្គោលរីស៊ត និងអញ្ជើញជាកិត្តិយសក្នុងព្រះរាជពិធីលៀងសាយភោជន៍ ជាកិត្តិយសដ៏ខ្ពង់ខ្ពស់ជូន ឯកឧត្តម **ង្វៀន សួនហ៊្វុក** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម និងគណៈប្រតិភូ នៅព្រះបរមរាជវាំង

- បានផ្តល់សេវាជូន**ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុម កា អនុប្រធានទី១ ព្រឹទ្ធសភា** អញ្ជើញចូលរួមពីធីសម្ពោធវិមានកីឡដ្ឋាន នៃពហុកីឡាដ្ឋានជាតិមរតកតេជោ និងពិធីរាប់ថយក្រោយ៥០២ថ្ងៃ ដំណើរឆ្ពោះទៅកាន់ព្រឹត្តិការណ៍ប្រកួតកីឡា SEA Game- ASEAN Para Game

ឆ្នាំ២០២៣ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានកីឡដ្ឋាន នៃពហុកីឡាដ្ឋានជាតិមរតកតេជោ រាជធានីភ្នំពេញ

- បានផ្តល់សេវា និងអមដំណើរ**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** អញ្ជើញដឹកនាំក្រុមសមាជិក សមាជិកាព្រឹទ្ធសភាប្រចាំភូមិភាគទី៣ ចុះជួបសំណេះសំណាល ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ទាំង១២៧ឃុំ សង្កាត់ នៅទូទាំងខេត្តកណ្តាល

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធ និងចូលរួមក្នុងពិធីបូជាព្រះសព**សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ** ព្រះប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ, សពលោកជំទាវ **ឱ សុខុម** សមាជិកាគណៈ-កម្មការទី២ព្រឹទ្ធសភា និងសពលោកស្រី **ស ស៊ីន់** ដែលត្រូវជាបងស្រីបង្កើតសម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ នៅរាជធានីភ្នំពេញ និងខេត្តព្រះវិហារ

- បានរៀបចំ និងចាត់ចែងពិធីបុណ្យសព និងបញ្ចុះសពលោកជំទាវ **ឱ សុខុម** សមាជិកា គណៈកម្មការទី២ព្រឹទ្ធសភា នៅស្រុកត្បែងមានជ័យ ខេត្តព្រះវិហារ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះមូលដ្ឋាន ដើម្បីជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ជាពិសេសចុះឈ្វេងយល់អំពីវឌ្ឍនភាពការងារ ការផ្តល់សេវាសាធារណៈ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ឈ្វេងយល់អំពីដំណើរការចុះឈ្មោះបោះឆ្នោត និងពិនិត្យបញ្ជីឈ្មោះបោះឆ្នោត ការដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ព្រមទាំងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗចំនួន១០២លើក នៅមូលដ្ឋានរាជធានី-ភ្នំពេញ ខេត្តកំពង់ស្ពឺ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកោះកុង ខេត្តពោធិ៍សាត់ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តបន្ទាយមានជ័យ ខេត្តឧត្តរមានជ័យ ខេត្តព្រះវិហារ ខេត្តកំពង់ធំ ខេត្តកំពង់ឆ្នាំង ខេត្តត្បូងឃ្មុំ ខេត្តកំពង់ចាម ខេត្តក្រចេះ ខេត្តព្រៃវែង និងខេត្តស្វាយរៀង

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញចុះជួបសំណេះសំណាល និងសាកសួរសុខទុក្ខអាជ្ញាធរសង្កាត់ជ្រោយចង្វារ សង្កាត់ព្រែកតាសេក និងសង្កាត់ព្រែកលៀប ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ឯកឧត្តមអគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញដាក់កម្រងផ្កាគោរពវិញ្ញាណក្ខន្ធសព ឯកឧត្តម **ចាន់ វ៉ាស៊ី** រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម ដែលបានទទួលមរណភាព

- បានទទួលពាក្យបណ្តឹងចំនួន០១ករណី ផ្ញើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ

ដើម្បីដោះស្រាយចំនួន០១ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន០១ករណី និងកំពុងពិនិត្យសិក្សាចំនួន០៤ករណី ឆ្លើយតបទៅម្ចាស់បណ្ដឹងចំនួន០១ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្ដឹងពីស្ថាប័នពាក់ព័ន្ធចំនួន០១ករណី ព្រមទាំងទទួលឯកសារជូនជ្រាបពីក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនគណៈកម្មការចំនួន១២ករណី

- បានធ្វើបទបង្ហាញស្ដីពី រចនាសម្ព័ន្ធ តួនាទី ភារកិច្ច និងដំណើរការនីតិកម្មរបស់ព្រឹទ្ធសភា ជូនសាស្ត្រាចារ្យ និងនិស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រងសេដ្ឋកិច្ច ខេត្តបាត់ដំបងចំនួន១៩នាក់ និងមន្ត្រីរាជការអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និងអង្គភាពពាក់ព័ន្ធចំនួន១១២នាក់

- បានធ្វើសារលិខិតថ្វាយព្រះពរ និងជូនពរថ្នាក់ដឹកនាំជាតិ និងអន្តរជាតិ ក្នុងឱកាសពិធីបុណ្យចូលឆ្នាំថ្មី ឆ្នាំសកល ២០២២ និងក្នុងឱកាសចម្រើនជន្មាយុ

- បានធ្វើសាររំលែកទុក្ខជូនគ្រួសារសពសមាជិកព្រឹទ្ធសភា និងមន្ត្រីជាន់ខ្ពស់ចំនួន០២លើក

- បានផលិតទស្សនាវដ្តីប្រចាំខែធ្នូ ឆ្នាំ២០២១ ចំនួន៨០០ក្បាល

- បានផលិតសៀវភៅទិនានុលេខន៍ឆ្នាំ២០២២ ចំនួន២,៨០០ក្បាល, ប្រតិទិនព្រឹទ្ធសភាឆ្នាំ២០២២ ចំនួន២,៨០០ក្បាល និងប្រតិទិនកម្មវិធីការងារប្រចាំថ្ងៃឆ្នាំ២០២២ ចំនួន៥០០ក្បាល។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

- បានរៀបចំទីកន្លែង និងផ្ដល់សេវាក្នុងពិធីជំនួបសវនាការ និងសម្ដែងការគួរសម ជូន **សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្ដម **ង្វៀន សួនហ៊ុក** ប្រធានរដ្ឋនៃសាធារណរដ្ឋសង្គមនិយមវៀតណាម, ឯកឧត្ដម **ហ្សាក់ ប៉ឺឡេត** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋបារាំងតែងតាំងថ្មី ប្រចាំព្រះរាជាណាចក្រកម្ពុជា, ឯកឧត្ដម **អាំផៃ ឃីនដាវង្ស** ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យ-ប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជាទើបតែងតាំងថ្មី ប្រចាំប្រទេសនានាចំនួន០៣រូប រួមមាន ឯកឧត្ដម **ទុយ រី** ឯកអគ្គរាជទូតប្រចាំព្រះរាជាណាចក្រជប៉ុន ឯកឧត្ដម **កែវ ឈា** ឯកអគ្គ-រាជទូតប្រចាំសហរដ្ឋអាមេរិក និងម៉ិកស៊ិកូ និងឯកឧត្ដម **ផន ពៅ** ឯកអគ្គរាជទូតប្រចាំសាធារណ-រដ្ឋហ្វីលីពីន

- បានរៀបចំទីកន្លែង និងផ្ដល់សេវាក្នុងពិធីជំនួបសម្ដែងការគួរសម និងពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយឯកអគ្គរដ្ឋទូតតួកគី, ឯកអគ្គរដ្ឋទូតឥណ្ឌា, ឯកអគ្គរាជទូតព្រុយណេ, ឯកអគ្គរាជទូតម៉ាឡេស៊ី, ឯកអគ្គរដ្ឋទូតឥណ្ឌូនេស៊ី, ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ, ភារធារីតំណាងស្ថានទូតឥស្លាមប៉ាគីស្ថាន,

ក្រុមអ្នកវិនិយោគទុនមកពីសាធារណរដ្ឋប្រជាមានិតចិន និងកញ្ញា **ជេង គន្ធា** ស្ត្រីខ្មែរដំបូងសិក្សាជំនាញវិស្វកម្មវិទ្យាសាស្ត្រសម្ភារ នៅសហរដ្ឋអាមេរិក

- បានរៀបចំចាត់ចែងជូនលោកជំទាវប្រធានគណៈកម្មការទី៨ព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយតំណាងអង្គការ WHO ប្រចាំព្រះរាជាណាចក្រកម្ពុជា តាមប្រព័ន្ធវីដេអូ

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមកិច្ចប្រជុំ និងវេទិកានានាតាមប្រព័ន្ធវីដេអូ រួមមាន ៖ កិច្ចប្រជុំប្រចាំឆ្នាំលើកទី២៩ នៃវេទិកាសភាអាស៊ី-ប៉ាស៊ីហ្វិក(APPF-29) ផ្សាយចេញពីទីក្រុងសេអ៊ូលនៃសាធារណរដ្ឋកូរ៉េ, កិច្ចប្រជុំក្រុមការងារដើម្បីពិនិត្យ និងពិភាក្សាសេចក្តីព្រាងស្តីពី ការលើកលែងទណ្ឌិកៈនៃសភាប្រើភាសាបារាំង (APF) ផ្សាយចេញពីទីក្រុងប៉ារីសនៃសាធារណរដ្ឋបារាំង និងកិច្ចប្រជុំចំពោះកិច្ច(Ad-hoc) នៃវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិកទទួលបន្ទុកសុខភាពពិភពលោក ក្រោមប្រធានបទ "COVID-19 និងការយកចិត្តទុកដាក់អំពីសុខុមាលភាពបឋមនាពេលអនាគត"

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីក្នុងពិធីបិទសិក្ខាសាលាស្តីពីទិដ្ឋភាពទូទៅនៃទំនួលខុសត្រូវរបស់សភាក្នុងការពង្រឹងស្ថាប័ន តាមប្រព័ន្ធវីដេអូ និងបានជួបពិភាក្សាការងារជាមួយទីប្រឹក្សាស្ថានទូតជប៉ុន

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតចិន, ដៃគូភាគីចិន, ទីស្តីការគណៈរដ្ឋមន្ត្រី មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), វិទ្យាស្ថានសភាអាស៊ី(PCA), វិទ្យាស្ថានជាតិស្ថិតិ(NIS), វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន(NIPTICT), សមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុនCambodia Hosting, ក្រុមហ៊ុនKOHA និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានធ្វើរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៧ និងលើកទី៨ នីតិកាលទី៤

- បានប្រជុំពិនិត្យសេចក្តីព្រាងផែនការមេស្តីពី បរិវត្តកម្មព្រឹទ្ធសភាអេឡិចត្រូនិច (២០២១-២០៣០)

- បានប្រជុំបូកសរុបលទ្ធផលការងារសមាគមសង្គហៈមូលដ្ឋាននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំឆ្នាំ២០២១

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មីៗ

## ៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ

- បានទទួលលិខិតចូលចំនួន៤៩៩ច្បាប់ និងបញ្ជូនលិខិតចេញចំនួន៥៧ច្បាប់

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យ បរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ ចំណតរថយន្ត ការងារសន្តិសុខ និងសណ្តាប់ធ្នាប់ ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានបើកប្រាក់បៀវត្សប្រចាំខែធ្នូ ឆ្នាំ២០២១ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខា-ធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានរៀបចំរបាយការណ៍ចំណាយថវិកាកម្មវិធីប្រចាំខែធ្នូ ឆ្នាំ២០២១

- បានរៀបចំរបាយការណ៍ទូទាត់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងការបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បានរៀបចំបែបបទជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីផ្តល់ថវិកាដើមឆ្នាំ២០២២ ឱ្យបានលឿន

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន១៧ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន ១០ប័ណ្ណ

- បានបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសចំនួន០១វគ្គ មានសិក្ខាកាមចូលរួមចំនួន ០៤នាក់ និងបណ្តុះបណ្តាលធនធានមនុស្សក្រៅប្រទេសចំនួន០១វគ្គ មានសិក្ខាកាមចូលរួមចំនួន ០១នាក់

- បានជូនដំណឹងផ្សព្វផ្សាយអាហារូបករណ៍ ក្រោមជំនួយរបស់រដ្ឋាភិបាលជប៉ុន

- បានជួសជុលកែលម្អពង្រីកផ្នែកខាងមុខ និងផ្នែកខាងក្រោយសាលបណ្ណាល័យព្រឹទ្ធសភា

- បានបាំងស្មាតបតបិទបង្អួច និងរៀបចំបាវចនាជាតិខ្មែរ សាសនា ព្រះមហាក្សត្រ នៅបន្ទប់ប្រជុំគណៈកម្មការទី៧ព្រឹទ្ធសភា

- បានរៀបចំ Counter Coffee នៅសាលពិសេសខាងមុខសាលប្រជុំថ្មី

- បានបង្រួមសួនច្បារ ដើម្បីរៀបចំចំណតរថយន្តថ្មី នៅខាងមុខសាលប្រជុំខាងជើង និងសាលពិសេស

- បានទទួលម៉ាស៊ីនសម្អាតអនាម័យចំនួន០៤គ្រឿង

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានានាចំនួន០៩បួង

- បានចាត់ចែងកម្លាំងបាញ់ទឹកលាងផ្លូវ (P2) ចំនួន០២លើក និងកាប់ដើមស្វាយដួលរលំ

នៅច្រកចូល (P1)

- បានចាត់ចែងកម្លាំង និងប្រើប្រាស់រថយន្តបោសសម្អាតតាមដងផ្លូវ ក្នុងបរិវេណព្រឹទ្ធសភា និងនៅជាប់របងខាងមុខព្រឹទ្ធសភា

- បានជួសជុល កែលម្អហេដ្ឋារចនាសម្ព័ន្ធ អគារ បណ្តាញទឹក ត្រួតពិនិត្យជណ្តើរយន្ត ត្រួតពិនិត្យសត្វកណ្តៀរ និងផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ ព្រមទាំងបានប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៩៥គ្រឿង/លើក

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្តីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គ-លេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែធ្នូ និងប្រចាំឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួង ស្ថាប័ននានា

- បានធ្វើរបាយការណ៍ស្តីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំត្រីមាសទី៤ ឆ្នាំ២០២១។

### ៩.២-ការងារស្រាវជ្រាវ៖

- បានតាមដានការកាត់បន្ថយចំណាយរបស់រាជរដ្ឋាភិបាល និងសិក្សាស្រាវជ្រាវការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ ក្នុងអំឡុងពេលនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩

- បានផលិតព័ត៌មានច្បាប់ជាតិ និងអន្តរជាតិចំនួន៤៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែធ្នូ ឆ្នាំ២០២១ ចំនួន០៤ច្បាប់។

### ៩.៣-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone និងដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៥៦គ្រឿង។ បានបញ្ចូលព័ត៌មានស្តីពី សកម្មភាពរបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភាចំនួន២២ប្រធានបទ

- បានបន្តចាត់ចែងការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន៣៩លើក

និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៧លើក

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្តាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន ការផលិតខ្សែវីដេអូ ការបោះពុម្ព និងការថតផ្សព្វផ្សាយអំពីសម័យប្រជុំព្រឹទ្ធសភាឱ្យបានល្បឿនល្អ និងរលូន។

**៩.៤-ការងារពិធីការ៖**

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន១៦លើក

- បានតាមដាន និងចងក្រងសេចក្តីប្រកាសព័ត៌មាន និងសេចក្តីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន០៥ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំឆ្នាំ២០២១ចំនួន០១ច្បាប់។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៧២ច្បាប់

- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាពនៅមុខអគារក្រហម និងខ្លោងទ្វារធំព្រឹទ្ធសភាចំនួន០៩លើក

- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១៤ច្បាប់ ស្មើនឹង៥៩នាក់ និងធ្វើលិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន០៣ច្បាប់ ស្មើនឹង០៣នាក់

- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន១៤៨លើក

- បានផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ ប្រេងឥន្ធនៈ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៥៦សំណើ

- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២៦លើក មានអ្នកចូលរួមចំនួន៥២២នាក់

- បានសួរសុខទុក្ខថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានជំងឺ និងគ្រោះថ្នាក់ចរាចរណ៍ចំនួន០២នាក់

- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២៤០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានថតចម្លងឯកសារចំនួន១,២៦៦ច្បាប់ អស់ក្រដាសចំនួន១៨,១៦៨សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន៨០លើក ស្មើនឹង១៩១នាក់។ បានជួសជុល ប្តូរប្រេងម៉ាស៊ីន និងអាគុយរថយន្តចំនួន ០៦គ្រឿង

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានព្រឹទ្ធសភាចំនួន១០លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន១,៤០៩លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន១១លើក។

**III-ទិសដៅការងារខែមករា ឆ្នាំ២០២២**

***-បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឹតត្បិតឡើស័ក) ប្រឆាំងនឹងជំងឺកូវីដ-១៩ ក្នុងពេលវេលាថ្មីដែលចាប់បើកប្រទេសឡើងវិញ និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖***

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមលក្ខណៈនៃការវិលត្រលប់មកកាន់ភាពប្រក្រតីនៃការអនុវត្តមុខងារស្នូលទាំង៣៖ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និង

ពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៥ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ។ វត្តមានមន្ត្រី បុគ្គលិកត្រូវឈរលើគោលការណ៍សមមូលនៃទំហំការងារដើម្បីៈ**

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

- ត្រៀមប្រកាសទទួលស្គាល់លោកជំទាវ **ចឹក ហេង** សមាជិកាព្រឹទ្ធសភាថ្មី ជំនួសលោកជំទាវ **ឱ សុខុម** សមាជិកាគណៈកម្មការទី២ព្រឹទ្ធសភា ធ្វើបច្ចុប្បន្នភាពក្រុមនានាក្រោយការផ្លាស់ប្តូរថ្មី (ការផ្តល់ការិយាល័យ ស្វាករថយន្ត ប័ណ្ណសមាជិក និងរបបមូលដ្ឋានសម្រាប់សមាជិកថ្មី)

- ជ្រើសតាំងឯកឧត្តម **ញ៉ូវ សុង** ជាសមាជិកគណៈកម្មការសេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្ម ព្រឹទ្ធសភា ជំនួសលោកជំទាវ **ឱ សុខុម**។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងបើកសម័យប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៣ច្បាប់ ដូចខាងក្រោមៈ

១-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម

២-សេចក្តីព្រាងច្បាប់ស្តីពី វិសោធនកម្មច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីកម្ពុជា-កូរ៉េ (CKFTA)។

## ២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

## ៣- មុខងារតំណាង

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចូលរួមពិធីបុណ្យជាតិសំខាន់ៗ

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាៈ

+ត្រៀមពិធីសម្ពោធសមិទ្ធផលវត្តព្រែកជ្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិ៍វង្ស នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា ការងារពិធីការជាតិ និងស្ថាប័ន កម្មវិធីជំនួប កម្មវិធីផ្លូវការ និងសាសនា ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែនជាការតម្រូវនៃវិបទកូវីដ-១៩

-តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU)ជាមួយរាជបណ្ឌិត្យ-សភាកម្ពុជា ឥណ្ឌា និងប៉ាគីស្ថាន ការអនុវត្តកម្មវិធីវិទ្យាស្ថានក្រសួងការបរទេស វិទ្យាស្ថានសភា-អាស៊ី(PCA) និងវិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU) ឡើងវិញជាមួយដៃគូសំខាន់ៗរបស់វិទ្យាស្ថានសភាអាស៊ី(PCA)ជាមួយរដ្ឋសភា-ព្រឹទ្ធសភាបារាំង លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)។ តាមដានការអនុវត្តជំនួយចិនសម្រាប់បណ្ណាល័យអេឡិចត្រូនិច និងគម្រោងអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធីបណ្តុះបណ្តាលជាបន្តបន្ទាប់

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ និងដោយផ្ទាល់

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA...)។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU) ស្ដីពី កិច្ចសហប្រតិបត្តិការស្រាវជ្រាវ និងបណ្ដុះបណ្ដាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាជាមួយរាជបណ្ឌិត្យសភាកម្ពុជា និងសាលាភូមិន្ទរដ្ឋបាល

-ការកសាងថវិកាឆ្នាំថ្មី២០២២ ដោយគិតដល់តម្រូវការក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ ក្នុងឆមាសទី១ ឆ្នាំ២០២២៖ សម្អាងនៃតម្រូវការអនុវត្តភាពតំណាងរបស់ព្រឹទ្ធសភា អនុវត្តស្វែងរកជំនួយចិន និងដៃគូ ដើម្បីចាប់ផ្ដើមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ន

-បញ្ចប់ការជួសជុល កែលម្អអគារអតីតនាយកដ្ឋានព័ត៌មានវិទ្យា(ICT) ក្រោមអគារក្រហម និងការពង្រីកអគារបណ្ណាល័យ

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់ខែមករា ឆ្នាំ២០២២ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្ដោតលើការងារជាអាទិភាព សំខាន់ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+ធ្វៀតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្ដើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-អនុវត្តការងារដើមឆ្នាំ តាមបរិបទកូវីដ-១៩ ដោយសម្រេចឱ្យបាននូវការងារជាអាទិភាព លើកផែនការ និងកម្មវិធីការងាររបស់ស្ថាប័ន និងគ្រប់អង្គភាពឆ្នាំ២០២២។ ការទូទាត់ថវិកាប្រចាំឆ្នាំ ត្រូវអនុវត្តទាន់ពេលវេលាដោយស្មារតីទទួលខុសត្រូវ៖

+របាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងវិភាជន៍គម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ដើម្បីថ្លឹងយោបល់សម្រេចក្នុងវចនាសម្ព័ន្ធនយោបាយ

-ធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈម៖ គោលការណ៍តមជ្រើសរើសថ្មីរហូតឆ្នាំ២០៣០ មុខតំណែង សន្ទស្សន៍បៀវត្ស ត្រូវរក្សាស្ថានភាពដដែលរហូតមានការណែនាំថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត បម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានា

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មី វិធីសាស្ត្រថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្ថានទូតចិន គម្រោងជំនួយចិនក្នុងការសាងសង់ និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានា។ល។)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន

-បន្តការផលិតខ្សែវីដេអូអំពីប្រវត្តិអគារព្រឹទ្ធសភាក្នុងបរិវេណវិមានរដ្ឋចំការមន។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងខែធ្នូនេះ ថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងយ៉ាងយកចិត្តទុកដាក់គ្រប់ការដ្ឋាន ដើម្បីឈានទៅបិទបញ្ចប់ការងារស្របតាមផែនការប្រតិបត្តិដែលបានកំណត់នៅក្នុងឆ្នាំ២០២១ ព្រមទាំងបានរៀបចំផែនការប្រតិបត្តិសម្រាប់ឆ្នាំ២០២២។

ទន្ទឹមនឹងនេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំផ្តល់សេវាបានយ៉ាងល្អប្រសើរ ដោយបានរៀបចំ និងចាត់ចែងការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ចំនួន០១លើក និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤។ ជាពិសេស បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ជាអាទិភាពលើមុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង ដោយបានផ្តល់សេវាជូនគណៈកម្មការជំនាញទាំង១០ ចុះបំពេញបេសកកម្ម ជួបសវនាការការងារជាមួយក្រសួង និងស្ថាប័ននានា ព្រមទាំងអមដំណើរសមាជិកព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធ ចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីឈ្វេងយល់អំពីការអភិវឌ្ឍមូលដ្ឋាន ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ជាពិសេសអប់រំប្រជាពលរដ្ឋឱ្យរៀនរស់ជាប្រក្រតីក្នុងបរិបទនៃជំងឺកូវីដ-១៩ និងបាននាំយកគ្រឿងឧបភោគ បរិភោគ និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក ព្រមទាំងប្រជាពលរដ្ឋរងគ្រោះមហន្តរាយផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។ ចំពោះមុខងារកិច្ចសហប្រតិបត្តិការអន្តរជាតិ បានរៀបចំ និងចាត់ចែងបានយ៉ាងល្អប្រសើរ ជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបពិភាក្សាការងារជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិ ព្រមទាំងកិច្ចប្រជុំនានាប្រព្រឹត្តទៅដោយរលូន។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែមិគសិរ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២១

**អគ្គលេខាធិការ**

អ៊ុំ_សារឹទ្ធ